វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
Cambodian Rubber Research Institute

# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០១៩



# សកម្មភាព និងសមិទ្ធផលការងារឆ្នាំ២០១៩

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩

# អារម្ភកថា

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (*វសកក*) មានកិត្តិយសក្នុងការបង្ហាញជូននូវរបាយកាណ៍សកម្មភាពការងារស្រាវជ្រាវប្រចាំឆ្នាំ២០១៩ ដើម្បីជាព័ត៌មានដល់អ្នកពាក់ព័ន្ធទៅនឹងការងារស្រាវជ្រាវ និងផលិតកម្មដំណាំកៅស៊ូ។ របាយការណ៍នេះបង្ហាញជូននូវសកម្មភាពការងារស្រាវជ្រាវ និងសមិទ្ធផលចម្បងៗរបស់ការិយាល័យមានដូចជា (១)ការិយាល័យបង្កាត់ពូជ (២)ការិយាល័យដាំដុះ និងការពារ (៣)ការិយាល័យសរីរវិទ្យា និងអាជីវកម្ម (៤)មន្ទីរពិសោធន៍ជាតិយថាប្រភេទ ព្រមទាំងការិយាល័យពាក់ព័ន្ធមួយចំនួនទៀតក្រោមឱវាទ *វសកក*។

លទ្ធផលការងារដែលបង្ហាញជូនក្នុងរបាយការណ៍សកម្មភាពនេះ សម្រេចបានដោយសារ កិច្ចខិតខំប្រឹងប្រែងអនុវត្តការងារប្រកបដោយកិច្ចសហការយ៉ាងជិតស្និទ្ធរវាងមន្ត្រីរាជការ និយោជិត និងថ្នាក់ដឹកនាំ *វសកក* ទាំងអស់នៅក្នុងការពិសោធន៍ ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងការចូលរួមពីប្រតិបត្តិករកៅស៊ូពាក់ព័ន្ធទាំងអស់ ហើយនិងបណ្ដាដៃគូអន្តរជាតិផ្សេងទៀតមានដូចជាៈ CIRAD, IRRDB, AFD, CATAS, UNIDO, HRPP ព្រមជាមួយគ្នានោះ ដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាភិបាល និងជាពិសេសកិច្ចគាំទ្រនិងតម្រង់ទិសពីស្ថាប័នអាណាព្យាបាលរួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ ដើម្បីជំរុញការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជាប្រកបដោយវឌ្ឍនភាព និងចីរភាព។

ខ្ញុំសង្ឃឹមថា ប្រតិបត្តិករកៅស៊ូ និងអ្នកពាក់ព័ន្ធទាំងឡាយក្នុងវិស័យកៅស៊ូនឹងទទួលបាននូវព័ត៌មានផ្សេងៗពីការពិសោធន៍ ស្រាវជ្រាវដំណាំកៅស៊ូតាមរយៈរបាយការណ៍នេះ ព្រមទាំងចូលរួមសហការ ផ្ដល់នូវមតិគាំទ្រ កែលម្អនិងតម្រង់ទិសការងារពិសោធស្រាវជ្រាវ ហើយនិងការរៀបចំនូវរបាយការណ៍សកម្មភាពនេះឲ្យមានលក្ខណៈកាន់តែប្រសើរឡើង។

ថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩

**នាយក**
**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

**ម៉ក់ សុភាវាស្នា**

# មាតិកា

ទំព័រ


អារម្ភកថា ........ ii

១. សេចក្តីផ្តើម ........ 1

២. អង្គការលេខ និងស្ថានភាពបុគ្គលិក ........ 2

២.១. អង្គការលេខ ........ 2

២.២. ស្ថានភាពបុគ្គលិក ........ 3

៣. សមិទ្ធផល និងលទ្ធផលតាមផ្នែក ........ 3

៣.១. សមិទ្ធផល ........ 3

៣.១.១. ផ្នែកក្សេត្រសាស្ត្រ ........ 3

៣.១.២. ផ្នែកមន្ទីរពិសោធន៍យថាប្រភេទ ........ 4

៣.១.៣. ការបណ្តុះបណ្តាល ........ 5

៣.១.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ ........ 7

៣.២. លទ្ធផលតាមផ្នែក ........ 11

៣.២.១. ការិយាល័យបង្កាត់ពូជ ........ 11

៣.២.២. ការិយាល័យដាំដុះ និងការពារ ........ 12

៣.២.៣. ការិយាល័យសរីរវិទ្យា និងអាជីវកម្ម ........ 15

៣.២.៤. មន្ទីរពិសោធន៍ជាតិយថាប្រភេទ ........ 17

៣.៣. ការអនុវត្តថវិកាកម្មវិធី ........ 21

៣.៣.១. ចង្កោមសកម្មភាពទី១ ពង្រឹងការពិសោធន៍ និងស្រាវជ្រាវដំណាំកៅស៊ូ ........ 21

៣.៣.២. ចង្កោមសកម្មភាពទី២ ពង្រឹងគុណភាពផលិតផលកៅស៊ូស្របទៅតាមស្តង់ដារអន្តរជាតិ ........ 21

៣.៣.៣. ចង្កោមសកម្មភាពទី៣ ពង្រឹងយន្តការទ្រទ្រង់ដល់ការស្រាវជ្រាវ និងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........ 22

៤. ការបោះពុម្ព និងផ្សព្វផ្សាយ ........ 22

៥. ទិសដៅការងារឆ្នាំ២០១៩ និងសន្និដ្ឋាន ........ 23

៥.១. ទិសដៅការងារឆ្នាំ២០១៩ ........ 23

៥.២. សេចក្តីសន្និដ្ឋាន ........ 23

៦. ការប្រជុំ និងសិក្ខាសាលា ........ 24

៦.១. ការប្រជុំ និងសិក្ខាសាលាក្នុងប្រទេស ........ 24

៦.២. ការប្រជុំ និងសិក្ខាសាលានៅក្រៅប្រទេស ........ 31

៧. រូបភាពសកម្មភាពផ្សេងទៀត ........ 35

## ១. សេចក្តីផ្តើម

កៅស៊ូធម្មជាតិជាដំណាំសេដ្ឋកិច្ច និងយុទ្ធសាស្ត្រយ៉ាងសំខាន់ ដែលផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនលើសលប់ដល់អ្នកដាំ ផ្តល់ជាចំណូលដល់សេដ្ឋកិច្ចជាតិនិងសង្គម ព្រមទាំងបរិស្ថាន។ ជាការឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្រលើកស្ទួយវិស័យកសិកម្ម នៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលអាណត្តិទី៦ ផែនការសកម្មភាពជាតិស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ក្រសួងកសិកម្មបានលើកឡើងនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្ម ២០១៩-២០២៣ ទិសដៅគោលនយោបាយរួមសំដៅ ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់៤%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកំពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព។ ក្នុងបរិបទនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចដាក់ឲ្យអនុវត្តនូវកម្មវិធីចំនួន៥ ក្នុងនោះ ***វសកក*** ស្ថិតនៅក្នុងកម្មវិធីទី១ គឺ៖ បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងពង្រីកកសិ-ធុរកិច្ច។

***វសកក*** ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតក្រោមអាណាព្យាបាលចំនួនពីរគឺ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ ព្រមជាមួយនឹងការដឹកនាំតម្រង់ទិសពីអង្គការកំពូលមួយគឺ ក្រុមប្រឹក្សាភិបាល។ ***វសកក*** ត្រូវបានប្រគល់ភារកិច្ចឲ្យអនុវត្តការងារនៅក្នុងកម្មវិធីទី១ និងអនុកម្មវិធីទី៧ ស្តីអំពី៖ «**ការលើកកម្ពស់គុណភាពពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ** » ដែលក្នុងនោះមានចង្កោមសកម្មភាព០៣ គឺ៖ ១.៧.១. *ការអភិរក្ស និងអភិវឌ្ឍក្លូនកៅស៊ូ ហើយនិងការសិក្សាអនុវត្តកសិកម្មល្អក្នុងការដាំដុះនិងថែទាំកៅស៊ូ ។* ១.៧.២. *ការសិក្សានិងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូ។* ១.៧.៣. *គាំទ្រលើដំណើរការពិសោធន៍ស្រាវជ្រាវ។*

របាយការណ៍សកម្មភាពនេះគឺជាសមិទ្ធផលសំខាន់ៗ របស់ ***វសកក*** ឆ្លើយតបទៅនឹងគោលនយាបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍកសិកម្ម ២០១៩-២០២៣ ហើយនិងផែនការរយៈពេលខ្លី មធ្យម និងវែងរបស់ ***វសកក*** ទៅតាមសូចនាករដែលបានគ្រោងទុកនៅក្នុងកម្មវិធី និងអនុកម្មវិធីដែលបានកំណត់ សំដៅរួមចំណែកក្នុងការបង្កើនផលិតភាពនិងតម្លៃបន្ថែមទៀត បង្កើនប្រភពចំណូលដល់កសិករ និងសេដ្ឋកិច្ចជាតិ ហើយនិងការអភិវឌ្ឍដំណាំកៅស៊ូប្រកបដោយនិរន្តរភាព។

## ២. អង្គការលេខ និងស្ថានភាពបុគ្គលិក

### ២.១. អង្គការលេខ




<u>**យោង៖**</u> -អនុក្រឹត្យលេខ២៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

-អនុក្រឹត្យលេខ២៨អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមមាត្រា៥ ចំណុច៥.១ នៃអនុក្រឹត្យលេខ២៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧

***វសកក*** ជាអង្គភាពគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមរយៈអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧ ក្នុងនោះបានចង្អុលបង្ហាញអំពីភារកិច្ច ដែលមានខ្លឹមសារថា៖ ***វសកក*** មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ និងការពិសោធន៍ សំដៅជម្រុញការអភិវឌ្ឍលើគ្រប់ផ្នែក នៃដំណាំកៅស៊ូទូទៅ និងចូលរួមរាល់សកម្មភាពនៃការជម្រុញ ផ្នែកបច្ចេកទេសសុវឌ្ឍកម្មនៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម។ នៅក្នុងអនុក្រឹត្យមានកាតព្វកិច្ចចំនួន៦ ចំណុចសំខាន់ ដែលត្រូវបានរំលេចឡើង សំដៅលើការអនុវត្តឲ្យបានសម្រេចឆ្លើយតបទៅនឹងភារកិច្ចខាងលើ។

ឆ្លើយតបទៅនឹងការអនុវត្តភារកិច្ចខាងលើ អង្គការលេខមួយត្រូវបានរៀបចំឡើង ដើម្បីចង្អុលបង្ហាញអំពីកាតព្វកិច្ចរបស់បណ្តាការិយាល័យ និងបណ្តាអង្គភាពចំណុះរបស់ ***វសកក*** តាមរយៈប្រកាសលេខ៥៧៦ ប្រក.កសក.បុ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣។ យោងសេចក្តីប្រកាសនេះ ***វសកក*** មានការិយាល័យ និងអង្គភាពចំណុះចំនួន៧ រួមមាន៖

១- ការិយាល័យ រដ្ឋបាល និងបុគ្គលិក

២- ការិយាល័យ ផែនការ និងគណនេយ្យ

៣- ការិយាល័យ បង្កាត់ពូជ

៤- ការិយាល័យ ដាំដុះ និងការពារ

៥- ការិយាល័យ សរីរវិទ្យា និងអាជីវកម្ម

៦- មន្ទីរពិសោធន៍ជាតិយថាប្រភេទ មានថ្នាក់ស្មើការិយាល័យ

៧- ស្ថានីយ៍អនុវត្ត មានថ្នាក់ស្មើការិយាល័យ

### ២.២ ស្ថានភាពបុគ្គលិក

មន្ត្រី ***វសកក*** ក្នុងក្របខ័ណ្ឌមុខងារសាធារណៈបច្ចុប្បន្នមានចំនួនសរុប៤៣នាក់ ក្នុងនោះមានស្ត្រី១០នាក់ និងកម្មករកិច្ចសន្យាផ្នែកចៀរជ័រ ដាំដុះ រោងចក្រ គ្រូបង្រៀន និងការងារបម្រើសេវាផ្សេងៗទៀត ដែលមានចំនួនសរុប២៦៣នាក់។ មន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំង៤៣នាក់មានកម្រិតសញ្ញាបត្រដូចខាងក្រោម៖

| | |
|---|---|
| + បណ្ឌិត | ០១នាក់ |
| + បរិញ្ញាបត្រជាន់ខ្ពស់ | ០៦នាក់ |
| + បរិញ្ញាបត្រ | ៣១នាក់ |
| + បរិញ្ញាបត្ររង | ០៣នាក់ |
| + បឋមឯកទេស | ០២នាក់ |
| និងមន្ត្រីជាប់កិច្ចសន្យា | ២០នាក់ |

## ៣. សមិទ្ធផល និងលទ្ធផលតាមផ្នែក

### ៣.១. សមិទ្ធផល

ការបំពេញភារកិច្ចក្នុងឆ្នាំ២០១៩ ក៏ដូចបណ្តាឆ្នាំមុនៗកន្លងមកដែរ ***វសកក*** បានខិតខំបន្តអនុវត្តការងារពិសោធន៍ និងស្រាវជ្រាវឆ្លើយតបទៅនឹងបរិបទនៃការអភិវឌ្ឍដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការបង្កើត ***វសកក*** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

#### ៣.១.១. ផ្នែកក្សេត្រសាស្ត្រ

- អនុវត្តការពិសោធន៍នូវបច្ចេកវិទ្យាថ្មី៖ ១. ការបំបៅកូនកៅស៊ូតូច(Mini budding) ២.ការរៀបចំកូនស្ទួមកៅស៊ូក្នុងបំពង់( Root trainer)

- ការបន្តតាមដាន និងយកទិន្នន័យចម្ការពិសោធមានចំនួន៦២ក្នុងបរិវេណស្ថានីយ៍អនុវត្តនិងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម
- រៀបចំរួចរាល់នូវមន្ទីរពិសោធវិភាគគីមីកសិកម្ម ដីនិងស្លឹក
- អង្កេតអំពីការប្រើប្រាស់ក្លូនកៅស៊ូក្នុងចំការនៅខេត្ត រតនគីរី ស្ទឹងត្រែង ព្រះវិហារ សៀមរាប ឧត្តមានជ័យ ប៉ៃលិន និង ពោធិ៍សាត់
- ទទួលក្លូនកៅស៊ូចំនួន១៧ក្លូនគឺៈ៥ក្លូនពីចំការកៅស៊ូ SOCFIN-KCD និង១២ក្លូនពី RRI-CATAS (ប្រទេសចិន) និងផ្តល់ក្លូនកៅស៊ូចំនួន១១ក្លូនទៅឱ្យ RRI-CATAS (ប្រទេសចិន)
- សិក្សាតាមដានលើការពិសោធអំពីសក្តានុពលទិន្នផលកៅស៊ូលើប្រព័ន្ធចង្វាក់ចៀរជ័រ d4 និងការប្រៀបធៀបសក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរ d3, d4, d5 និង d6
- ការរៀបចំបើកមុខចៀរចម្ការពិសោធន៍ក្លូនកៅស៊ូទ្រង់ទ្រាយធំចំនួន០១ពិសោធន៍ នៅក្រុមហ៊ុនចម្ការកៅស៊ូ SOC-FIN KCD ស្ថិតនៅខេត្តមណ្ឌលគិរី
- វិភាគសរីរសាស្ត្រទឹកជ័រ (LD) ចម្ការពិសោធន៍នានាក្នុងនិងក្រៅស្ថានីយបានចំនួន២៨ចម្ការពិសោធន៍ស្មើនឹង៨៤៨ សំណាក
- រៀបចំរបាយការណ៍បច្ចេកទេសប្រចាំឆ្នាំ២០១៨-២០១៩

### ៣.១.២. ផ្នែកមន្ទីរពិសោធន៍យថាប្រភេទ

- ចូលរួមធ្វើតេស្ត (Round Robin) ចំនួន២ដងជាមួយប្រទេសម៉ាឡេស៊ី
- អនុវត្តការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទតាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2005
- ធ្វើតេស្តវិភាគសំណាកយថាប្រភេទកៅស៊ូចំនួន៣៦៨ភាគសំណាកសម្រាប់ធ្វើការវាយតម្លៃសមត្ថភាព និង គុណភាពជ័រដែលបានកែច្នៃដោយរោងចក្រចំនួន១០ក្រុមហ៊ុន
- ការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក (Laboratories Parallel Test) លើកទី៦០ ដើម្បីវាយតម្លៃមន្ទីរពិសោធន៍មូលដ្ឋានយោងតាមប្រកាសលេខ៤០៤ប្រក.កសក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨
- ការផ្តល់សុពលភាពបន្ត លើការទទួលស្គាល់និងការអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា របស់រោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍ក្រុមហ៊ុនស៊ីហ្វ វីសសស៍ (ខេមបូឌា) លីមីធីត
- ចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ (CSR) និងមន្ទីរពិសោធន៍មូលដ្ឋានបាន៥ក្រុមហ៊ុនគឺៈ

  +ក្រុមហ៊ុនស៊ី.អ.ស៊ី.ខេ.២ អភិវឌ្ឍន៍កៅស៊ូ ខូ.,អិលធីឌី ដែលមានអាសយដ្ឋានៈ ភូមិថ្នះដើម ឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំ

  +ក្រុមហ៊ុនហ៊ាង អាន ម៉ាង យ៉ាង ខេ អភិវឌ្ឍន៍កៅស៊ូ ខូ., អិលធីឌី ដែលមានអាសយដ្ឋានៈ ភូមិគងយុត ឃុំប៉ាតេ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី

  +ក្រុមហ៊ុនដុង ភូក្រចេះ អភិវឌ្ឍន៍កៅស៊ូ ខូ., អិលធីឌី ដែលមានអាសយដ្ឋានៈ ភូមិអូរព្រះ ឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ

  +ក្រុមហ៊ុនភឿក វ៉ា កំពង់ធំ អភិវឌ្ឍន៍កៅស៊ូ ខូ., អិលធីឌី ដែលមាន អាសយដ្ឋានៈ ភូមិសង្គ្រោះ ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ

  +ក្រុមហ៊ុនសុកហ៊្វីន ដែលមានអាសយដ្ឋានភូមិប៊ូស្រា ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី។

### ៣.១.៣. ការបណ្ដុះបណ្ដាល

#### ❖ ការបណ្ដុះបណ្ដាលផ្ទៃក្នុង

ក្នុងការពង្រឹងគុណភាព និងសមត្ថភាពធនធានមនុស្សក្នុងការងារស្រាវជ្រាវ នៅឆ្នាំ២០១៩នេះ **វសកក** បានបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្ដុះបណ្ដាលផ្សេងៗ ក្នុងនោះរួមមាន៖

➢ សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាលក្នុងប្រទេស:

- មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី "ក្រុមការងាររៀបចំចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform)" នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ត្រីចំនួន០១រូប បានចូលរួមសិក្សាវគ្គបណ្ដុះបណ្ដាល គ្រប់គ្រងហិរញ្ញវត្ថុ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មន្ត្រីចំនួន០២រូប ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្ដីពីការរៀបចំផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ នៅខេត្តសៀមរាប
- មន្ត្រីចំនួន០២រូប ចូលរួមសិក្ខាសាលាស្ដីពីការរៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធី នៅខេត្តកំពង់ធំ
- មន្ត្រីចំនួន០២រូប ចូលរួមសិក្ខាសាលាស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩ នៅខេត្តសៀមរាប
- មន្ត្រីចំនួន០២រូប ចូលរួមសិក្ខាសាលាស្ដីពីផែនការពង្រឹង និងអភិវឌ្ឍប្រព័ន្ធអេកូនវានុវត្តន៍ និងសហគ្រិនភាព នៅក្រសួងផែនការ
- មន្ត្រីចំនួន០១រូប ចូលរួមសិក្ខាសាលាស្ដីពីការអនុវត្តកិច្ចព្រមព្រៀងកសិកម្ម(AoA) និងកិច្ចព្រមព្រៀង SPS ក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងការជំរុញការនាំចេញផលិតកម្មកសិកម្ម នៅខេត្តកំពត
- មន្ត្រីចំនួន០៤រូប ចូលរួមសិក្ខាសាលាបូកសរុបលទ្ធផលការងារពិការភាព នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ត្រីចំនួន០១រូប ចូលរួមសិក្ខាសាលាស្ដីពីឧស្សាហកម្មកៅស៊ូធម្មជាតិ នៅខេត្តកំពត
- មន្ត្រីចំនួន០១រូប ចូលរួមសិក្ខាសាលាស្ដីពីការគ្រប់គ្រងដំណាំកៅស៊ូ នៅខេត្តពោធិសាត់
- មន្ត្រីចំនួន០១រូប ចូលរួមសិក្ខាសាលាស្ដីពីការពិនិត្យឡើងវិញនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ឆ្នាំ២០១៩-២០២៣ នៅខេត្តកំពង់ចាម
- មន្ត្រីចំនួន០៣រូប ចូលរួមវគ្គបណ្ដុះបណ្ដាលនៅសាលាភូមិន្ទរដ្ឋបាល ភ្នំពេញ
- មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០២០-២០២២ នៅខេត្តកំពត
- មន្ត្រីចំនួន០១រូប ចូលរួមសិក្ខាសាលាស្ដីពីយន្តការនិងនីតិវិធីសម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ត្រីចំនួន០១រូប ចូលរួមសិក្ខាសាលាស្ដីពីបច្ចេកទេសប្រើប្រាស់និងថែរក្សាបរិក្ខារមន្ទីរពិសោធន៍នៅសាលាជាតិកសិកម្មព្រែកលាប
- មន្ត្រីចំនួន០១រូប ចូលរួមសិក្ខាសាលាស្ដីពីពិនិត្យឡើងវិញលើការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធី នៅខេត្តកំពត

- មន្ត្រីចំនួន០២រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការ លទ្ធកម្មសាធារណៈ នៅក្រសួងសេដ្ឋកិច្ច
- មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុនិគ្រប់គ្រងថវិកា នៅក្រសួងសេដ្ឋកិច្ច
- មន្ត្រីចំនួន០២រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសស្តីពីរដ្ឋទេយ្យករចំណូលនិងរដ្ឋទេយ្យករចំណូលរង នៅក្រសួងសេដ្ឋកិច្ច
- មន្ត្រីចំនួន០២រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសស្តីពីរដ្ឋទេយ្យករបុរេប្រទាននិងរដ្ឋទេយ្យករបុរេប្រទានរង នៅក្រសួងសេដ្ឋកិច្ច

## ➢ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលក្រៅប្រទេស:

- មន្ត្រីចំនួន០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការកែច្នៃផលិតផលកៅស៊ូនៅប្រទេសថៃ
- មន្ត្រីចំនួន០៧រូប បានទៅចូលរួមសិក្ខាសាលាអន្តរជាតិសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ (IRRDB) នៅប្រទេសមីយ៉ាន់ម៉ា
- មន្ត្រីចំនួន០២រូប បានចូលរួមនិងធ្វើបទបង្ហាញក្នុងសន្និសីទកៅស៊ូអន្តរជាតិឆ្នាំ២០១៩ នៅប្រទេសមីយ៉ាន់ម៉ា។
- មន្ត្រីចំនួន០១រូបបានទៅចូលរួមសិក្ខាសាលានិងប្រជុំផ្នែកបង្កាត់ពូជកៅស៊ូនៅប្រទេសម៉ាឡេស៊ី
- មន្ត្រីចំនួន០២រូបបានទៅចូលរួមសិក្ខាសាលា និងប្រជុំនៃបណ្ឌិតសភា វិទ្យាសាស្ត្រកសិកម្មត្រូពិកចិន(Chinese Academy of Tropical Agricultural Sciences-CATAS) នៅប្រទេសចិន
- មន្ត្រីចំនួន១រូប បានទៅចូលរួមសិក្ខាសាលាជីជាតិដីនិងការអនុវត្តកសិកម្មល្អនិងផលិតកម្ម (Soil fertility, Good Agriculture Practices and Productivity) និងកិច្ចប្រជុំអ្នកជំនាញកៅស៊ូដើម្បីពិភាក្សាលើជំងឺកៅស៊ូដែលកំពុងកើតមានឡើងថ្មីៗ (IRRDB meeting of the experts on new leaf diseases )នៅទីក្រុង Melaka និងទីក្រុង Kuala Lumpur ប្រទេសម៉ាឡេស៊ី
- មន្ត្រីចំនួន១រូប បានទៅចូលរួមនិងធ្វើបទបង្ហាញក្នុងកិច្ចប្រជុំលើកដំបូងនៃគណៈកម្មាធិការបច្ចេកទេសស្តីពីការការពារដំណាំនៅទីក្រុងគូឡាឡាំពួប្រទេសម៉ាឡេស៊ី
- មន្ត្រីចំនួន១រូប បានទៅចូលរួមប្រជុំការងារស្រាវជ្រាវកៅស៊ូនៅប្រទេសថៃ
- មន្ត្រីចំនួន១រូបបានទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ឧស្សាហកម្មនិងសម័យប្រជុំថ្នាក់ជាតិលើកទី៥២ នៅប្រទេសសឹង្ហបុរី

## ❖ ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ

ក្នុងការរួមចំណែកដល់ការអភិវឌ្ឍដំណាំកៅស៊ូ ទន្ទឹមគ្នានឹងការអភិវឌ្ឍផ្នែកធនធានមនុស្ស **វសកក** បានយកចិត្តទុកដាក់ដល់ការបណ្តុះបណ្តាល ផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងផ្សេងៗទៅដល់ប្រតិបត្តិករកៅស៊ូ សំដៅផ្តល់នូវចំណេះដឹង ចំណេះធ្វើ ហើយនិងបង្កើននូវភាពជឿជាក់និងឱកាសជោគជ័យ នៅក្នុងការវិនិយោគលើផលិតកម្មដំណាំកៅស៊ូ។ ការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ ត្រូវបានអនុវត្តលើគ្រប់មុខជំនាញទៅតាមវិធីសាស្ត្រផ្សេងៗដែលអាចធ្វើទៅបានមានដូចជា៖

- ការបើកវគ្គបណ្តុះបណ្តាល និងការបង្ហាញនៅនឹងកន្លែងលើមុខជំនាញផ្សេងៗ ពាក់ព័ន្ធនឹងដំណាំកៅស៊ូ
- ការទទួលកសិករធ្វើទស្សនកិច្ចសិក្សា
- ការប្រាស្រ័យទាក់ទងតាមប្រព័ន្ធព័ត៌មានវិទ្យា និងការផ្លាស់ប្តូរព័ត៌មាន

# តារាងសរុបនៃការបណ្តុះបណ្តាលធនធានមនុស្ស:

## ការបណ្តុះបណ្តាល និងផ្ទេរបច្ចេកវិទ្យា

| ល.រ | ឆ្នាំ | មន្ត្រី | ជន បង្គោល | ផ្ទេរ ប.ច ដល់ និស្សិត | ដឹកនាំសារណា | សិក្ខាសាលា | បណ្តុះបណ្តាល កសិករ | ភ្ញៀវ ទស្សនកិច្ច. | សរុប |
|---|---|---|---|---|---|---|---|---|---|
| 1 | 1997 | 0 | 0 | 0 | 4 | 57 | 20 | 2 | 83 |
| 2 | 1998 | 0 | 0 | 0 | 1 | 0 | 5 | 2 | 8 |
| 3 | 1999 | 0 | 0 | 0 | 3 | 0 | 5 | 35 | 43 |
| 4 | 2000 | 0 | 20 | 0 | 0 | 0 | 14 | 2 | 36 |
| 5 | 2001 | 20 | 50 | 0 | 0 | 200 | 20 | 1 | 291 |
| 6 | 2002 | 22 | 98 | 0 | 2 | 0 | 35 | 4 | 161 |
| 7 | 2003 | 14 | 90 | 0 | 2 | 72 | 104 | 2 | 284 |
| 8 | 2004 | 12 | 40 | 0 | 9 | 55 | 22 | 2 | 140 |
| 9 | 2005 | 15 | 27 | 0 | 4 | 0 | 25 | 3 | 74 |
| 10 | 2006 | 21 | 120 | 0 | 6 | 180 | 40 | 20 | 387 |
| 11 | 2007 | 25 | 315 | 0 | 0 | 320 | 70 | 220 | 950 |
| 12 | 2008 | 0 | 0 | 25 | 1 | 65 | 120 | 7 | 218 |
| 13 | 2009 | 12 | 150 | 42 | 2 | 70 | 150 | 20 | 446 |
| 14 | 2010 | 10 | 41 | 70 | 13 | 250 | 180 | 5 | 569 |
| 15 | 2011 | 12 | 57 | 27 | 9 | 92 | 170 | 2 | 369 |
| 16 | 2012 | 7 | 48 | 24 | 12 | 125 | 220 | 7 | 443 |
| 17 | 2013 | 13 | 200 | 110 | 17 | 53 | 390 | 3 | 786 |
| 18 | 2014 | 13 | 10 | 161 | 13 | 196 | 280 | 11 | 684 |
| 19 | 2015 | 7 | 15 | 72 | 22 | 70 | 295 | 5 | 486 |
| 20 | 2016 | 10 | 25 | 100 | 13 | 354 | 350 | 225 | 1077 |
| 21 | 2017 | 4 | 20 | 32 | 8 | 227 | 345 | 25 | 657 |
| 22 | 2018 | 27 | 5 | 10 | 10 | 30 | 35 | 20 | 137 |
| 23 | 2019 | 14 | 0 | 22 | 8 | 0 | 0 | 72 | 116 |
| សរុប | | **236** | **1331** | **685** | **159** | **2386** | **2895** | **693** | **8445** |

### ៣.១.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងទិសដៅពង្រឹងការងារស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាកៅស៊ូដល់ប្រតិបត្តិករឲ្យកាន់តែមានប្រសិទ្ធភាព ហើយនិងការទាញយកអត្ថប្រយោជន៍បច្ចេកវិទ្យាកៅស៊ូ ពីបណ្តាប្រទេសអភិវឌ្ឍនានា ***វសកក*** បានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាវិទ្យាស្ថាន និងអង្គការអន្តរជាតិជាច្រើនរួមមាន៖

❖ ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB)

គឺជាបណ្តាញស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ ដែលប្រមូលផ្តុំរាល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូធម្មជាតិស្ទើរតែគ្រប់ប្រទេសផលិតកៅស៊ូធម្មជាតិទាំងអស់ដែលមាន៩៥% នៃបរិមាណផលិតផលកៅស៊ូធម្មជាតិនៃពិភពលោក។ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយបណ្តាប្រទេសជាសមាជិក IRRDB និងការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូកម្ពុជា ប្រទេសកម្ពុជាបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ នៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងសិក្ខាសាលាអន្តរជាតិផ្សេងៗ។ នៅឆ្នាំ២០១៦ **កម្ពុជា** បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិស្តីអំពី « **និរន្តរភាពនៃឧស្សាហកម្មកៅស៊ូធម្មជាតិ បញ្ហា ការប្រឈម និងកាលានុវត្តភាព** » ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដោយមានគណៈប្រតិភូពីបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិចំនួន១៦ និងប្រទេសជាដៃគូចំនួន០២ផ្សេងទៀត ព្រមជាមួយនិងភ្ញៀវចូលរួមសរុបចំនួន៣៣០ នាក់។ នៅឆ្នាំ២០១៧ ***វសកក*** បានសហការជាមួយ IRRDB ក្នុងការរៀបចំសិក្ខាសាលាអន្តរជាតិ IRRDB-Workshop ស្តីអំពី ***"ការផ្ទេរបច្ចេកវិទ្យាដល់ផលិតករកៅស៊ូ និងកៅស៊ូគ្រួសារ"*** ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃ ទី១២-១៣ ខែកក្កដា ឆ្នាំ២០១៧ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ ដោយមានភ្ញៀវពីបណ្តាសមាជិក IRRDB ចំនួន០៩ ប្រទេសគឺ៖ **កម្ពុជា ចិន ថៃ បារាំង ម៉ាឡេស៊ី ស្រីលង្កា ហ្វីលីពីន វៀតណាម និងអូស្ត្រាលី** អញ្ជើញចូលរួមសរុបចំនួន១៦៩នាក់។

### ❖ កិច្ចសហប្រតិបត្តិការជាមួយ CIRAD

ក្នុងការពង្រឹងសមត្ថភាពនិងបង្កើននូវប្រសិទ្ធិភាពសិក្សាស្រាវជ្រាវអំពី បច្ចេកទេសនិងវិទ្យាសាស្ត្រដំណាំកៅស៊ូ ***វសកក*** បានធ្វើសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្ម សម្រាប់ការអភិវឌ្ឍ (CIRAD) នៃប្រទេសបារាំង ដោយបានចុះអនុស្សរណៈនៃការយោគយល់គ្នាមួយកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ នៅ ***វសកក***។ ផ្អែកលើអនុស្សរណៈនេះក្នុងឆ្នាំ២០១៩ ជំនាញការ CIRAD បានបំពេញបេសកកម្មចំនួន ០២ដងមកកាន់កម្ពុជា ដែលលើកទី០១គឺ៖ នៅថ្ងៃទី១០-១២ ខែមិថុនា ឆ្នាំ២០១៩ ជំនាញការ CIRAD បានអញ្ជើញមកទស្សនកិច្ច និងពិភាក្សាការងារស្រាវជ្រាវកៅស៊ូ ជាមួយមន្ត្រីស្រាវជ្រាវកៅស៊ូរបស់ CRRI នៅស្ថានីយពិសោធន៍របស់វិទ្យាស្ថានស្ថិតក្នុងខេត្តត្បូងឃ្មុំ។ ក្នុងនោះផងដែរ ថ្នាក់ដឹកនាំ ***វសកក*** និងសហការីបានរួមដំណើរជាមួយជំនាញការ CIRAD ចូលរួមប្រជុំជាមួយ និងថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិកាលើការ កសាងសមត្ថភាព (capacity building) ដល់និស្សិតថ្នាក់អនុបណ្ឌិត និងបណ្ឌិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ លើកទី០២គឺ៖ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ លោកបណ្ឌិត Bruno Rapidel និងលោកបណ្ឌិត Eric Gohet ជំនាញការ CIRAD មកដើម្បីជួបប្រជុំស្តីពីលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបាននូវកិច្ចសហការស្រាវជ្រាវកៅស៊ូឱ្យកាន់តែប្រសើរឡើង។ ឆ្លៀតក្នុងឱកាសនេះដែរ ជំនាញការ CIRAD ក៏បានធ្វើទស្សនកិច្ចនៅឡូត៍ពិសោធន៍ រោងចក្រកែច្នៃកៅស៊ូសន្លឹក និងមន្ទីរពិសោធន៍របស់ ***វសកក*** ផងដែរ។

ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ លោក **ម៉ក់ សុភាវាស្នា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងថ្នាក់ដឹកនាំវិទ្យាស្ថាន បានជួបពិភាក្សាការងារជាមួយលោកបណ្ឌិត Bruno Rapidel និងលោកបណ្ឌិត Eric Gohet ជំនាញការ CIRAD ស្តីពីលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបាននូវកិច្ចសហការស្រាវជ្រាវកៅស៊ូឱ្យកាន់តែប្រសើរឡើង។ ឆ្លៀតក្នុងឱកាសនេះដែរ លោកបណ្ឌិតជំនាញការ CIRAD ក៏បានធ្វើទស្សនកិច្ចនៅឡូត៍ពិសោធន៍ រោងចក្រកែច្នៃកៅស៊ូសន្លឹក និងមន្ទីរពិសោធន៍របស់វិទ្យាស្ថានផងដែរ។






## ❖ កិច្ចសហប្រតិបត្តិការជាមួយ CATAS

កិច្ចសហប្រតិបត្តិការរវាង **វសកក** និងបណ្ឌិតសភា វិទ្យាសាស្ត្រកសិកម្មត្រូពិកចិន(Chinese Academy of Tropical Agricultural Sciences-CATAS) ត្រូវបានរៀបចំឡើង ដោយបានចុះអនុស្សរណៈនៃការយោគយល់ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុង កូឡុមបូ ប្រទេស ស្រីលង្កា។ ក្នុងទិសដៅបង្កើននូវទំនាក់ទំនង និងសកម្មភាពស្រាវជ្រាវអំពីដំណាំកៅស៊ូ។ បន្ទាប់មក **វសកក** និង CATAS បានចុះអនុស្សរណៈនៃការយោគយល់បំពេញបន្ថែមចំនួនពីរលើកគឺនៅឆ្នាំ២០១៨មួយលើក និងឆ្នាំ២០១៩មួយលើក ដើម្បីបន្តសុពលភាពនៃកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវរួមគ្នា។ ក្នុងឆ្នាំ២០១៩ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ **វសកក** ទៅទស្សនកិច្ចនៅប្រទេសចិនចំនួន៤លើក និងបានបណ្តុះបណ្តាលរយៈពេលខ្លីដល់មន្ត្រី **វសកក** ចំនួន៣រូបនៅប្រទេសចិននិងបន្តការពិសោធរួមគ្នាដូចជាការរៀបចំបង្កើតចម្ការពិសោធន៍ សាកល្បងថ្នាំព្យាបាលជំងឺស្ងួតមុខចៀរ (TPD Recovery) ចម្ការពិសោធន៍សាកល្បងការចៀរជ័រដោយម៉ាស៊ីន អំពីការបំបៅកូនកៅស៊ូតូច (Mini Budding) អំពីការរៀបចំកូនកៅស៊ូក្នុងបំពង់ Root Trainer និងការងារច្បារបង្កាត់ពូជ មិនតែប៉ុណ្ណោះភាគី CATAS បានជួយរៀបចំមន្ទីរពិសោធន៍គីមី កសិកម្ម ដី និងស្លឹក ដល់ **វសកក។** ការបំបៅកូនកៅស៊ូតូច (mini-budding) និងកូនកៅស៊ូ root trainer នេះជាបច្ចេកទេសថ្មី ដែលមន្ត្រីក្នុងការិយាល័យដាំដុះបានសិក្សាពីអ្នកជំនាញនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន(CATAS) និងត្រូវយកមកអនុវត្តសាកល្បង។ CATAS បានជួយបង្ហាត់បង្រៀនមន្ត្រីពីជំនាញនៃដំណើរការវិភាគសំណាកដី ស្លឹក ក៏ដូចជាផ្តល់សម្ភារ ឧបករណ៍ និងម៉ាស៊ីនសម្រាប់វិភាគសំណាកផងដែរ។ ហើយការសហប្រតិបត្តិការនេះ និងបន្តនូវបណ្តាឆ្នាំបន្តបន្ទាប់ទៀត។



ការពិភាក្សា និងផ្តល់យោបល់ រវាង **វសកក** និង CATAS



ការចុះហត្ថលេខារួមគ្នារវាង CRRI និង CATAS





ការបណ្តុះបណ្តាលមន្ត្រី វសកក ជាមួយ ជំនាញការCATAS

ថ្ងៃទី២៣ ខែមេសា ដល់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៩ គណៈប្រតិភូវិទ្យាស្ថានស្រាវជ្រាវកៅស៊ូនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS) បានអញ្ជើញមកទស្សនកិច្ចនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (CRRI) ក្នុងគោលបំណងដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវកៅស៊ូរួមគ្នា។ ក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ ក្រុមការងារ CATAS និងក្រុមការងារ CRRI ក៏បានរួមគ្នាចុះសិក្សាអង្កេតអំពី ការប្រើប្រាស់ក្លូនកៅស៊ូក្នុងការដាំដុះ ការប្រើប្រាស់ដីលើដំណាំកៅស៊ូ និងការចៀរប្រមូលផលកៅស៊ូនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូ និងចម្ការកៅស៊ូគ្រួសារនៅក្នុងខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី កំពង់ធំ ព្រះវិហារ និងខេត្តសៀមរាបផងដែរ។





ការចុះទស្សនកិច្ចរបស់ ជំនាញការCATAS នៅស្ថានីយ៍អនុវត្តន៍ និងនៅតាមបណ្តាចម្ការកៅស៊ូ



ជំនាញការ RRI,CATAS ពន្យល់ពីរបៀបប្រើប្រាស់



ការប្រើប្រាស់ម៉ាស៊ីន Atomic Absorption Spectro photometer

## ៣.២. លទ្ធផលតាមផ្នែក

### ៣.២.១. ការិយាល័យបង្កាត់ពូជ

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

- ស្រង់ទិន្នន័យជ័រកៅស៊ូចំការពិសោធន៍ក្នុងនិងក្រៅស្ថានីយសរុបបានចំនួន១៥ចំការពិសោធន៍
- រៀបចំទីតាំង និងស្រង់ទិន្នន័យជំងឺ *Oidium* នៃចំការពិសោធន៍កូនក្នុងនិងក្រៅស្ថានីយបានចំនួន១៥៖ *IRAA01,IRAA02, IRAA03, IRAA04,IRAA05, IRAA06, IRAA07, IRAA08, IRAA09, IRAA10, MKAA01, KRAA01, KRAA02, KRAA04 KRAA05*
- ថែទាំច្បារពូជកៅស៊ូទំហំ ៨ហិកតាសម្រាប់បំរើដល់ការពិសោធន៍ស្រាវជ្រាវ
- វាស់ទំហំដើមកៅស៊ូបានចំនួន១១ចំការពិសោធន៍៖ *IRAA06, IRAA07, IRAA08, IRAA09, IRAA10, IRAA12, SSCT01, SSCT02, PVAA01, PVAA02 និង MKAA01*
- រៀបចំបើកចៀរជ័រដំបូងចំការពិសោធន៍បានចំនួន១(IRAA10 លើផ្ទៃដីប្រមាណ ៦,០៦ ហ.ត)
- ទទួលពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ច្បារពូជកៅស៊ូបានចំនួន១ច្បាប់(កសិករមកពីស្រុកចំការលើខេត្ត កំពង់ចាម)។



ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ មន្ត្រី **វសកក** បានចុះបំពេញកាងារនៅក្រុមហ៊ុន SOCFIN KCD CO., LTD ដើម្បីពិនិត្យទិន្នន័យពិសោធន៍ និងរៀបចំទីតាំងសម្រាប់ប្រមូលទិន្នន័យជំងឺ Oidium ដែលកើតមានលើកូនកៅស៊ូនីមួយៗ ក្នុងចម្ការពិសោធកូនទ្រង់ទ្រាយធំ (LSCT) ស្ថិតនៅឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី

### ៣.២.២. ការិយាល័យដាំដុះ និងការពារ

សកម្មភាពការងារដែលបានអនុវត្តរួមមាន៖

- ការស្រាវជ្រាវប្រើប្រាស់ជី និងបរិមាណសមាសធាតុ N.P.K ទៅលើការលូតលាស់ ហើយនិងទិន្នផលជ័រដែលទទួលបានពីការដាក់ជីលើចម្ការពិសោធន៍សរុបចំនួន០៦
- ការស្រាវជ្រាវពិពិធកម្មដំណាំចន្លោះរងកៅស៊ូ ចំនួន៥ប្រភេទ ចេក ខ្នុរ ស្វាយ ម្នាស់ និង ស្វាយចន្ទី
- ការស្រាវជ្រាវឥទ្ធិពលនៃដំណាំគ្របដីនិងការប្រើប្រាស់ជីទៅលើការលូតលាស់ និងទិន្នផលកៅស៊ូ ដោយក្នុងនោះមានដំណាំគម្របដី ៣ប្រភេទគឺ *Stylosanthes guianensis*, *Mucuna aterrinum* និង *Pueraria phaseoloides*
- ការស្រាវជ្រាវលើការស្រោចស្រពកូនកៅស៊ូលើផ្ទៃដី៣.៤៦ហ.ត
- ការថែទាំ និងគ្រប់គ្រងកូនកៅស៊ូមិនទាន់ឱ្យផលត្រូវបានអនុវត្តជាប្រចាំក្រោយពីការដាំដុះ ដែលជាទូទៅមានរយៈពេលមធ្យមចំនួន៦ឆ្នាំ មុននឹងដាក់បញ្ចូលក្នុងដំណាក់កាលជាកៅស៊ូប្រមូលផល។ ផ្ទៃដីនៃការដាំដុះកៅស៊ូក្នុងឆ្នាំ២០១៩ ក្លូន PMB1 មានទំហំ៦.៥ហ.ត។ ផ្ទៃដីមិនទាន់ប្រមូលផលនៅក្នុងដំណាក់កាលថែទាំក្នុងឆ្នាំ២០១៩ មានចំនួន៩០.២៥ហ.ត ។
- បានបាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកុលាប ទៅលើកៅស៊ូផ្តល់ផល និងមិនទាន់ផ្តល់ផល ចាប់ពីអាយុ៣ទៅ១០ឆ្នាំ លើផ្ទៃដី២១២ហ.ត។
- ថ្នាលបណ្តុះកូនកៅស៊ូក្នុងឆ្នាំ២០១៩ ត្រូវបានរៀបចំចំនួន០,៣៥ហ.ត ដើម្បីបង្កើតជាជើងទម្រសម្រាប់ផ្តល់ឱ្យការបំបៅ និងយកទៅដាំដុះពិសោធន៍។

❖ ការពិសោធអំពីការប្រើប្រាស់ជីនៅលើដំណាំកៅស៊ូ

***វសកក*** បានរៀបចំការពិសោធន៍អំពី ការប្រើប្រាស់ជីលើដំណាំកៅស៊ូ ដើម្បីពិនិត្យ និងអង្កេតអំពីឥទ្ធិពលនៃប្រភេទជី ហើយនិងបរិមាណសមាសធាតុ N.P.K ទៅលើការលូតលាស់ នៃកូនកៅស៊ូ ហើយនិងទិន្នផលជ័រដែលទទួលបានពីការដាក់ជីពិសោធន៍ នៅលើកៅស៊ូដែលកំពុងផ្តល់ផលតើមានការខុសប្លែកគ្នាយ៉ាងណាធៀបទៅនឹងកៅស៊ូដែលមិនបានដាក់ជី ដើម្បីមានមូលដ្ឋានធ្វើការសម្រេចចិត្តថាតើត្រូវប្រើជីឬយ៉ាងណា សម្រាប់ចងក្រងជាទិន្នន័យក្នុងការវិភាគ និងផ្តល់ជាអនុសាសន៍ដល់កសិករ។



សកម្មភាពមន្ត្រី ***វសកក*** ចុះប្រមូលទិន្នន័យលូតលាស់របស់ដំណាំកៅស៊ូនៅខេត្តកោះកុង និងខេត្តពោធិ៍សាត់



សកម្មភាពដាក់ជីបំប៉នលើដំណាំកៅស៊ូក្នុងចំការពិសោធន៍នៅស្ថានីយអនុវត្ត ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

### ❖ ចម្ការពិសោធន៏អំពីការធ្វើពិពិធកម្មដំណាំចន្លោះរងកៅស៊ូ

***វសកក*** បានរៀបចម្ការពិសោធន៍ចំនួនពីរក្នុងឆ្នាំ២០១៨ (១)ឥទ្ធិពលនៃដំណាំចន្លោះរងលើការលូតលាស់និងទិន្នផលកៅស៊ូ ក្នុងគោលបំណង វាយតម្លៃឥទ្ធិពលនៃដំណាំចន្លោះរងលើការលូតលាស់ និងទិន្នផលកៅស៊ូ ហើយនិងប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំចន្លោះរងកៅស៊ូ (២)ឥទ្ធិពល និងផលប៉ះពាល់នៃដំណាំគ្របដី និងការប្រើប្រាស់ជីទៅលើការលូតលាស់និងទិន្នផលកៅស៊ូ ហើយនិងការបង្កើតជីវម៉ាស់គ្រប់គ្រងជីជាតិដី។



ការត្រួតពិនិត្យ និងថែទាំចម្ការពិសោធន៍អំពីការធ្វើពិពិធកម្មប្រភេទដំណាំផ្សេងៗ រួមមាន៖ ដំណាំស្វាយ, ស្វាយចន្ទី, ចេក, ម្នាស់  នៅតាមចន្លោះរងកៅស៊ូ នៅស្ថានីយអនុវត្ត ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

## ❖ បន្តការតាមដានចម្ការពិសោធន៍

ការតាមដាន និងស្រង់ទិន្នន័យចម្ការពិសោធន៍ត្រូវបានអនុវត្តជាប្រចាំ ក្រោយពីការដាំដុះចម្ការពិសោធន៍រួច។ ការតាមដានស្រង់ទិន្នន័យចម្ការពិសោធន៍ ត្រូវប្រើប្រាស់ពេលវេលាយូរចាប់ពី០៥-២៥ឆ្នាំ ទៅតាមប្រភេទនៃការពិសោធន៍។ សកម្មភាពដែលបានអនុវត្តមានដូចខាងក្រោមៈ

- ការធ្វើស្ថិតិចំនួនដើមដាំរស់ និងងាប់
- ការដាំជួសកូនកៅស៊ូដែលងាប់
- ការវាស់វែងទំហំដើមតាមដានការលូតលាស់ត្រូវបានអនុវត្តន៍គ្រប់ៗដើម នៃការពិសោធន៍ជារៀងរាល់ឆ្នាំម្តងឬពីរដងទៅតាមពិធីសារពិសោធន៍ដែលបានតម្រូវ
- ការស្រង់ទិន្នន័យទិន្នផល
- ការវិភាគទិន្នន័យ
- ការរៀបចំរបាយការណ៍លទ្ធផលនៃការពិសោធន៍



ការបំបៅកូនកៅស៊ូតូច (mini budding)



ការផ្សាំកូនកៅស៊ូតូច (mini budding) ក្នុងបំពង់ Root Trainer



ការបាញ់ថ្នាំការពារ និងព្យាបាលកូនកៅស៊ូ



ការប្រមូលទិន្នន័យទឹកជ័រនៅចំការពិសោធន៍

សកម្មភាពការថែទាំចម្ការពិសោធន៍នៅស្ថានីយអនុវត្ត នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

### ៣.២.៣. ការិយាល័យសរីរវិទ្យា និងអាជីវកម្ម

សកម្មភាពការងារ និងលទ្ធផលការងារចម្ការពិសោធន៍ដែលបានអនុវត្តរួមមាន៖

- ស្រង់ទិន្នន័យ និងបញ្ចូលទិន្នន័យទឹកជ័រចម្ការពិសោធន៍សក្តានុពលទិន្នផល លើប្រព័ន្ធចង្វាក់ចៀរជ័រ (d3, d4) ចំនួន៩ចម្ការ ចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀររង្វើល (d3, d4, d5, d6) ចំនួន២ចម្ការ និងចម្ការពិសោធន៍ចៀរជ័រដោយម៉ាស៊ីន (Tapping Machine) ចំនួន១ចម្ការ
- វាស់ទំហំដើមកៅស៊ូតាមដានការលូតលាស់លើចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ (d3) ចំនួន៣ចម្ការ ប្រព័ន្ធចង្វាក់ចៀរជ័ររង្វើល (d3, d4, d5, d6) ចំនួន២ចម្ការ និងចម្ការពិសោធន៍ការបើកមុខចៀរទំហំដើមខុសៗគ្នាចំនួន១ចម្ការ
- ស្រង់ទិន្នន័យដើមចៀរ និងជម្ងឺស្ងួតមុខចៀរ TPD គ្រប់បណ្តារចំការពិសោធន៍នីមួយៗ ក្នុងស្ថានីយនិងក្រៅស្ថានីយ
- ចុះពិនិត្យការអូសក្រិតប្តូរមុខចៀរលើចម្ការពិសោធន៍ សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ(d3, d4) ចំនួន៥ (IRAE02, IRAE03, IRAE05 ,IRAE09, IRAE10 និង IRAE13)
- ត្រួតពិនិត្យតាមដានការសារប្រមូលផលទឹកជ័រគ្រប់បណ្តាចម្ការពិសោធន៍
- ចុះបេសកកម្មស្រង់ទិន្នន័យ វាស់ទំហំដើមតាមដានការលូតលាស់ ជំងឺស្ងួតមុខចៀរ (TPD) និងអូសក្រិតប្តូរផ្ទាំងចៀរតាមបច្ច័យនៃពិធីសាពិសោធន៍ នៅក្រុមហ៊ុនចម្ការកៅស៊ូក្រែក (KRAE03)
- វិភាគរកស្តង់ដាសរីរសាស្ត្រទឹកជ័រ (LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (RSH)
- រៀបចំបង្កើតចម្ការពិសោធន៍សាកល្បងថ្នាំព្យាបាលជំងឺស្ងួតមុខចៀរ (TPD Recovery)
- បាញ់ថ្នាំ លាបថ្នាំព្យាបាល និងដាក់ជីដើមកៅស៊ូស្ងួតមុខចៀរលើចម្ការពិសោធន៍សាកល្បងថ្នាំព្យាបាលជំងឺស្ងួតមុខចៀរ និងបិទស្លាកកូដសំគាល់បច្ច័យពិសោធន៍
- ថែទាំនិងសម្អាតស្មៅចន្លោះរងចម្ការពិសោធន៍ TPD Recovery និង Tapping Machine
- រៀបចំសរសេររបាយការណ៍បច្ចេកទេសប្រចាំឆ្នាំ(Annual Technical Report )។
- ចូលរួមនិងធ្វើបទបង្ហាញចំនួន១ នៅសន្និសីទកៅស៊ូអន្តរជាតិឆ្នាំ២០១៩ នៅប្រទេសមីយ៉ាន់ម៉ា។





សកម្មភាពអូសក្រិតប្តូរផ្ទាំងចៀរ

សកម្មភាពវាស់ និងកត់ត្រាទិន្នន័យទឹកជ័រ
ចម្ការពិសោធន៍





សកម្មភាពលាបថ្នាំ និងបាញ់ថ្នាំព្យាបាលជំងឺស្ងួតមុខចៀរ





សកម្មភាពយកសំណាទឹកជ័រ និងវិភាគសរីរសាស្ត្រទឹកជ័រ

❖ ផ្នែកមន្ទីរពិសោធន៍ជីវគីមី និងសរីរវិទ្យា

- លាយសូលុយស្យុងវត្ថុធាតុគីមីចំនួន១០មុខ សម្រាប់វិភាគរកស្តង់ដារ និងវិភាគសរីរសាស្ត្រទឹកជ័រ
- វិភាគរកស្តង់ដាសរីរសាស្ត្រទឹកជ័រលើប៉ារ៉ាម៉ែត្របី Inorganic Phosphorus (Pi), Sucrose(Suc) ,និង Thiol (R-SH) បានចំនួន០៤ដងក្នុង១ខែ ដើម្បីផ្ទៀងផ្ទាត់វត្ថុធាតុគីមី
- វិភាគបរិមាណជ័រស្ងួត DRC ចំការពិសោធនីមួយៗ តាមវិធីសាស្ត្រឧបករណ៍មេត្រូឡាក់ និងតាមមន្ទីរពិសោធន៍បានចំនួនបីដងលើ១៤ចំការពិសោធន៍។
- វិភាគសរីសាស្ត្រទឹកជ័រគ្រប់បណ្តាចំការពិសោធន៍នានាក្នុងស្ថានីយ

❖ មន្ត្រីការិយាល័យសរីរវិទ្យា និងអាជីវកម្ម បេសកកម្មត្រួតពិនិត្យចម្ការពិសោធន៍ ក្នុងក្រុមហ៊ុនចម្ការកៅស៊ូក្រែក រៀងរាល់ខែដើម្បីៈ

- ពិនិត្យបច្ចេកទេសប្រមូលផលទឹកជ័រ
- ពិនិត្យស្ថានភាពទូទៅចម្ការពិសោធន៍
- ត្រួតពិនិត្យការរៀបចំសម្ភារៈប្រមូលផលទឹកជ័រ
- ពិនិត្យតាមដានការសាប្រមូលផលទឹកជ័រ
- វាស់ទឹកជ័រតាមបច្ច័យនៃសារនីមួយៗ
- វិភាគរកបរិមាណជ័រស្ងួត (DRC) គ្រប់បច្ច័យនៃសារនីមួយៗ
- តាមដានការលាបថ្នាំរំញោចអេតេហ្វូន (Ethephon)។

### ៣.២.៤. មន្ទីពិសោធន៍ជាតិយថាប្រភេទ

មន្ទីរពិសោធន៍យថាប្រភេទគឺជាផ្នែកដ៏សំខាន់មួយរបស់ **វសកក** និងជាមន្ទីរពិសោធន៍ជាតិដែលមានតួនាទីនៅក្នុងការពង្រឹងគុណភាពផលិតកម្មកៅស៊ូធម្មជាតិកម្ពុជា។ សកម្មភាពការងាររបស់មន្ទីពិសោធន៍ក្នុងឆ្នាំ២០១៩ រួមមានៈ

- អនុវត្តការងារមន្ទីរពិសោធន៍ជាតិយថាប្រភេទ តាមប្រពន្ធ័គ្រប់គ្រងគុណភាព ISO/IEC 17025 : 2005
- ការធ្វើតេស្តប្រៀបធៀបមន្ទីពិរសោធន៍ក្នុងស្រុក (Parallel tests) សម្រាប់ឆ្នាំ២០១៩
- បានទៅចូលរួមប្រជុំពីរលើក នៅអគ្គនាយកដ្ឋានកៅស៊ូ ស្តីពីការកែសម្រួលសារាចរណ៍ណែនាំ"ការជំរុញការអនុវត្ត និងការបំពេញបែបបទការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ Cambodian Specified Rubber (CSR) សម្រាប់នាំចេញ
- បានទទួលប្រតិភូ នៃវេទិកាដៃគូស្រាវជ្រាវកៅស៊ូ (HRPP) មកទស្សនកិច្ច នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការស្រាវជ្រាវរួមគ្នារវាង HRPP និង CRRI
- បានទទួលនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម មកទស្សនកិច្ចសិក្សា នៅក្នុងមន្ទីរពិសោធន៍ជាតិយថាប្រភេទ បានចំនួនមួយដង
- បានធ្វើលិខិតសេចក្តីថ្លែងហេតុ តាមរយៈអគ្គនាយកដ្ឋានកៅស៊ូ ស្តីពីសារាចរណ៍ណែនាំ "ការជំរុញការអនុវត្ត និងការបំពេញបែបបទការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់នាំចេញ"
- បានទទួលនិស្សិតមកពី វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មកសិក្សាស្រាវជ្រាវពីការតង់សូម៉ែត្រ (ឧបករណ៍ការទាញជ័រ) ដើម្បីផលិតពូកមកសិក្សា នៅក្នុងមន្ទីរពិសោធន៍ជាតិយថាប្រភេទ បានចំនួនមួយដង
- បានទៅចូលរួមប្រជុំ ២ដង ស្តីពី"ក្រុមការងាររៀបចំចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform)" នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានទៅចូលរួមប្រជុំ ស្តីពី"ក្រុមការងាររៀបចំចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform)" នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទៅចូលរួមប្រជុំ ២ដង ស្តីពី"ក្រុមការងារសិក្សាស្រាវជ្រាវអាស៊ីតអំបិល" នៅអគ្គនាយកដ្ឋានកៅស៊ូ
- បានទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការកែច្នៃផលិតផលកៅស៊ូនៅប្រទេសថៃ និងបានទៅចូលរួមសន្និសីទនៅប្រទេសភូមា
- មានការបណ្តុះបណ្តាល ដល់មន្ត្រីមន្ទីរពិសោធន៍ជាតិយថាប្រភេទរយៈពេលមួយខែ ដោយជំនាញការបរទេស
- បានចូលរួមធ្វើតេស្តប្រៀបធៀបលើកទី១២០ និង១២១ (Tests Round Robin 120th-121th) ជាមួយប្រទេសម៉ាឡេស៊ី បាន២ដង
- បានបណ្តុះបណ្តាលដល់និស្សិតមកសាលាជាតិកសិកម្មកំពង់ចាម មកសរសេររបាយការណ៍ នៅមន្ទីរពិសោធន៍ជាតិយថាប្រភេទ ក្នុងរយៈពេលមួយខែ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្ររង
- បន្តការងារចុះត្រួតពិនិត្យ និងវាយតម្លៃរោងចក្រកែច្នៃកៅស៊ូ (CSR) និងមន្ទីរពិសោធន៍មូលដ្ឋាន ២ដងក្នុងមួយឆ្នាំ
- បានទទួលប្រតិភូ នៃវេទិកាដៃគូស្រាវជ្រាវកៅស៊ូ (HRPP) មកទស្សនកិច្ច នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការ ស្រាវជ្រាវរួមគ្នា រវាង HRPP និងCRRI
- ការពិសោធន៍ស្រាវជ្រាវ លើការប្រើប្រាស់អាស៊ីត៣ប្រភេទ ដែលមានកំហាប់ខុសៗគ្នា នៅស្ថានីយអនុវត្តនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

  ១- Sulfuric acid 1% ដែលមាន pH=4.6, pH=5, pH=5.4 ទៅលើក្លូន GT1 និង PB260

  ២- Formic acid 1.5% ដែលមាន pH=4.6, pH=5, pH=5.4 ទៅលើក្លូន GT1 និង PB260

  ៣- អាស៊ីតម្ស៉ៅ តាមរបៀបកសិករ (១គីឡូលាយទឹក៥លីត្រ) ទៅលើក្លូន GT1 និង PB260







សកម្មភាពនៃការចុះកម្មសិក្សារបស់និស្សិត សកលវិទ្យាល័យ នៅមន្ទីពិសោធន៍ជាតិយថាប្រភេទនៃ **វសកក**





ការវិភាគវីស្កូម៉េត្រមូនី

ការវិភាគពណ៌





សកម្មភាព នៃការធ្វើតេស្តអសុទ្ធភាព

ការវិភាគ Po និង PRI





សកម្មភាព នៃការដុត ដើម្បីតេស្តវិភាគផេះ

សកម្មភាព កិនសំណាកជ័រ ឲ្យស្មើសាច់

ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ **លោក ម៉ក់ សុភាទាស្លា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងសហការី បានចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា រវាងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងក្រុមហ៊ុនសុកហ្វីនកម្ពុជា( ដែលប្រព្រឹត្តទៅនៅសាលប្រជុំក្រុមហ៊ុនសុកហ្វីនកាសេដេ ស្ថិតនៅឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។ បន្ទាប់ពីចុះហត្ថលេខារួច លោកនាយក និងមន្ត្រីជំនាញរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានចុះពិនិត្យនិងវាយតម្លៃរោងចក្រកែច្នៃជ័រកៅស៊ូ និងមន្ទីរពិសោធន៍វិភាគគុណភាពកៅស៊ូ ដើម្បីចុះបញ្ជិកា ផ្តល់សិទ្ធិប្រើប្រាស់ស្លាកសញ្ញា និងទទួលស្គាល់ជាមន្ទីរពិសោធន៍មូលដ្ឋាន ពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។











### ៣.៣ ការអនុវត្តថវិកាកម្មវិធី

**វសកក** ជាគ្រឹះស្ថានសាធារណៈ និងជាអង្គភាពថវិកា ហើយស្ថិតក្នុងអនុកម្មវិធីទី៧ ស្តីអំពី៖ **លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ ក្នុងគោលបំណង** ធ្វើឲ្យមានប្រសិទ្ធភាពខ្ពស់ពូជកៅស៊ូថ្មីបន្សាំបាននឹងការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យផលិតផលកៅស៊ូកម្ពុជាមានតម្លៃខ្ពស់លើទីផ្សារអន្តរជាតិ។ ដែលក្នុងនោះមានចង្កោមសកម្មភាព០៣គឺៈ ១. ការអភិរក្សនិងអភិវឌ្ឍន៏ក្លូនកៅស៊ូ ហើយនិងការសិក្សាអនិវត្តកសិកម្មល្អក្នុងការដាំដុះ និងថែទាំកៅស៊ូ។ ២. ការសិក្សា និងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូ។ ៣. គាំទ្រលើដំណើរការពិសោធន៍ស្រាវជ្រាវ។

#### ៣.៣.១.ចង្កោមសកម្មភាពទី១ ការអភិរក្សនិងអភិវឌ្ឍន៏ក្លូនកៅស៊ូ ហើយនិងការសិក្សាអនិវត្តកសិកម្មល្អក្នុងការដាំដុះ និងថែទាំកៅស៊ូ

ក្នុងគោលបំណងពីរសំខាន់គឺ៖ ១. ការបង្កើតក្លូនកៅស៊ូ និងទិន្នន័យក្លូនកៅស៊ូមានលក្ខណៈសមស្របទៅនឹងស្ថានភាពប្រទេសកម្ពុជា ដើម្បីជាគ្រឹះនៃការធ្វើអនុសាសន៍ និងប្រភពទិន្នន័យសម្រាប់វិភាគ និងវាយតម្លៃ។ ២. ប្រើប្រាស់ដីឲ្យបានប្រសិទ្ធិភាពក្នុងការថែទាំនិងបំប៉នកៅស៊ូគ្រប់ស្ថានភាពដី និងប្រមូលទិន្នន័យដើម្បីវិភាគនិងវាយតម្លៃ។ **វសកក** បានខិតខំកសាងនូវធនធានក្លូនកៅស៊ូឡើងវិញដោយការនាំចូលក្លូនកៅស៊ូពីបរទេស តាមរយៈនៃកិច្ចសហប្រតិបត្តិការជាដៃគូបច្ចេកទេសជាមួយបណ្តាអង្គការ មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្ម និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូនៃបណ្តាប្រទេសផ្សេងៗមួយចំនួន ដែលជាសមាជិកនៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ ហើយនិងការខិតខំអភិវឌ្ឍក្លូនកៅស៊ូជាតិ ដើម្បីជុំរុញការអភិវឌ្ឍវិស័យកៅស៊ូនៅកម្ពុជាប្រកបដោយនិរន្តរភាព។ បច្ចុប្បន្ន **វសកក** បានធ្វើការអភិរក្សក្លូនកៅស៊ូចំនួន៧៤ក្លូន រួមជាមួយនឹងការពង្រីកច្បារពូជប្រមាណ៦ហ.ត ក្នុងការផ្គត់ផ្គង់មែកពូជសម្រាប់ការបំបៅ ដើម្បីដាំដុះពិសោធន៍ និងចែករំលែកដល់ប្រតិបត្តិករ។

#### ៣.៣.២. ការសិក្សា និងអភិវឌ្ឍវិធីសាស្ត្រប្រមូលផលប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងគុណភាពផលិតផលកៅស៊ូ

ក្នុងគោលបំណងពីរសំខាន់គឺ៖ ១. បង្កើតប្រពន្ធ័ទិន្នន័យដោយផ្អែកលើសង្វាក់នៃការចៀរជ័រ និងស្ទង់ជារសរីរសាស្ត្រទឹកជ័រទៅតាមបណ្តាក្លូនគ្រប់រដូវកាល ។ ២. ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋានសម្រាប់ទទួលស្គាល់ជាផ្លូវការពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងពង្រឹងគុណភាពកែច្នៃនិងតាមដានលទ្ធផលធ្វើតេស្ត និងការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ។ ការប្រមូលផលសម្រាប់ដំណាំកៅស៊ូខុសពីការប្រមូលផលចំពោះដំណាំប្រភេទផ្សេងទៀត ការប្រមូលផលដំណាំកៅស៊ូទាមទារនូវពលកម្មដែលមានជំនាញច្បាស់លាស់ ជាមួយនឹងការអនុវត្តខ្ជាប់ខ្ជួនស្របទៅតាមបទដ្ឋានបច្ចេកទេសហើយមាន ផែនការនិងពេលវេលាកំណត់។ ការប្រមូលផលជ័រកៅស៊ូសមស្រប ដំណាំកៅស៊ូនឹងមានប្រក្រតីភាពក្នុងការលូតលាស់ និងសុខភាពល្អ អាចធានាបាននូវនិរន្តរភាពក្នុងការ ផ្តល់ផលបានយូរអង្វែងរហូតដល់២៥-៣០ឆ្នាំ។ ការប្រមូលផលកៅស៊ូមានការប្រែប្រួលទៅតាមដំណាក់ក្រោយពីការប្រមូលផល ជ័រកៅស៊ូត្រូវឆ្លងកាត់នូវដំណាក់កាលកែច្នៃបឋមជាទម្រង់ដុំ(TSR) ជាមុនសិន ទើបអាចធ្វើនិហរណកម្មបាន។ ផ្អែកលើលិខិតបទដ្ឋានគតិយុត្ត (អនុក្រិត្យលេខ៥៥អនក្រ.បក) ការធ្វើនិហរណកម្មជ័រកៅស៊ូកែច្នៃជាទម្រង់ដុំ(TSR) ត្រូវមានវិញ្ញាបនបត្របញ្ជាក់តាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជាដើម្បី៖ (១)បង្កើនគុណភាពនៃការកែច្នៃកៅស៊ូកម្ពុជា (២)ផ្តល់ជំនឿទុកចិត្តដល់អតិថិជនជាតិ និងអន្តរជាតិក្នុងពាណិជ្ជកម្មកៅស៊ូ (៣)លើកស្ទួយគុណភាពកៅស៊ូកម្ពុជាលើទីផ្សារអន្តរជាតិ (៤)ការពារសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (៥)សម្របសម្រួលការធ្វើអាជីវកម្ម ការកែច្នៃ ការនាំចេញ និងការធ្វើឯកជនភាវូបនីយកម្មយថាប្រភេទកៅស៊ូកម្ពុជា (៦)ការពារតម្លៃ និងបង្កើនភាពប្រកួតប្រជែងនៃកៅស៊ូកម្ពុជា (៧)បង្កើនចំណូលរដ្ឋលើពន្ធនាំចេញ ឬពន្ធផ្សេងទៀតពាក់ព័ន្ធនឹង បទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា។

### ៣.៣.៣. ចង្កោមសកម្មភាពទី៣ គាំទ្រលើដំណើរការពិសោធន៍ស្រាវជ្រាវ

ក្នុងគោលបំណង បង្កើនដំណើរការពិសោធន៍ និងស្រាវជ្រាវរបស់អង្គភាពបានប្រសើរឡើង។ ដើម្បីឲ្យការពិសោធន៍ និងស្រាវជ្រាវរបស់អង្គភាពមានការប្រសើរឡើងយើងគប្បី កសាងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ទាំងបរិមាណនិងគុណភាព ព្រមជាមួយគ្នានោះក៏មានការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីផ្តល់នូវភាពកក់ក្តៅក្នុងការរស់នៅ និងបរិស្ថានបំពេញការងារដល់មន្ត្រីនិងនិយោជិក ដែលជាចលករសំខាន់ចូលរួមនៅក្នុងការជំរុញដល់ការងារស្រាវជ្រាវ និងអភិវឌ្ឍប្រកបដោយជោគជ័យ និងចីរភាព។

## ៤. ការបោះពុម្ព និងផ្សព្វផ្សាយ

ឯកសារជាច្រើនប្រភេទត្រូវបានធ្វើការបោះពុម្ពផ្សាយ និងចែកចាយសំដៅផ្ទេរបច្ចេកវិទ្យា និងចែករំលែកព័ត៌មានដល់អ្នកបច្ចេកទេស អ្នកស្រាវជ្រាវ និងប្រតិបត្តិករកៅស៊ូ បានយល់ដឹងអំពី បច្ចេកទេសដាំដុះ ការគ្រប់គ្រងថែទាំកូនកៅស៊ូ ច្បារពូជ និងច្បារបង្កាត់ពូជ ការប្រើប្រាស់ជីក្នុងការថែបំប៉នកូនកៅស៊ូ និងទៅលើកៅស៊ូដែលកំពុងប្រមូលផល ការគ្រប់គ្រងជីជាតិដី បច្ចេកទេសនៃការប្រមូលផលទឹកជ័រ ការធ្វើពិពិធកម្មកៅស៊ូ ជាមួយប្រភេទដំណាំផ្សេងៗ រួមទាំងសកម្មភាពផ្សេងទៀតដែល **វសកក** បាននិងកំពុងអនុវត្ត។ នៅឆ្នាំ២០១៩ ឯកសារដែលវិទ្យាស្ថានបានបោះពុម្ពផ្សាយ និងចែកចាយដល់អង្គភាពពាក់ព័ន្ធ និងប្រតិបត្តិករកៅស៊ូរួមមាន៖

- សៀវភៅបច្ចេកទេសអភិវឌ្ឍន៍កៅស៊ូគ្រួសារនៅកម្ពុជាបានចំនួន៥០ក្បាល

**អនុសាសន៍ក្លូនកៅស៊ូនៅកម្ពុជាសម្រាប់ឆ្នាំ២០១៩-២០២០**

| ថ្នាក់១ | ថ្នាក់២ | ថ្នាក់៣ |
|---|---|---|
| IRCA 230<br>RRIM 600<br>PB 280<br>RRIC 121<br>IRCA 130 | GT 1<br>IRCA 109<br>RRIM 712<br>PB 235<br>PB 217<br>RRIC 101<br>RRIC 100<br>KV 4 | BPM 24<br>IRCA 111<br>IRCA 41<br>PR 303<br>PR 254<br>PB 310<br>PB 314<br>PB 324<br>PB 330<br>PR 261 |

## ៥.ទិសដៅការងារឆ្នាំ២០២០ និងសន្និដ្ឋាន

### ៥.១. ទិសដៅការងារឆ្នាំ២០២០

- បង្កើនការយកចិត្តទុកដាក់បន្តការងារស្រាវជ្រាវ
- ការយកចិត្តទុកដាក់ក្នុងការកសាងធនធានមនុស្ស បំពេញឲ្យធនធានមនុស្សដែលខ្វះខាត
- ពង្រឹងការអនុវត្តគម្រោងផែនការ និងសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២០ ឲ្យមានប្រសិទ្ធិភាព
- បន្តការយកចិត្តទុកដាក់លើការផ្ទេរបច្ចេកវិទ្យាដល់ប្រតិបត្តិករកៅស៊ូ
- បន្តការស្នើសុំបង្កើតទីតាំងអនុស្ថានីយ និងមន្ទីរពិសោធន៍
- បន្តបំពេញបេសកកម្មនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ ដែលបានចុះបញ្ជិកាជាមួយ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- ពង្រឹងការអនុវត្តលើការបំពេញបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូCSR សម្រាប់ការនាំចេញកៅស៊ូ
- អនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិកនៃ IRRDB
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសមាជិក IRRDB និងអង្គការអន្តរជាតិ ព្រមទាំងភាគីជាតិដូចជាបណ្តាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ ហើយនិងអន្តរាគមន៍រាល់សេវា បច្ចេកទេស បែបបទចុះបញ្ជិការោងចក្រ មន្ទីរពិសោធន៍
- ចូលរួមសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យា
- ចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានាក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើមុខវិជ្ជាបច្ចេកទេសដាំដុះ ការប្រមូលផលទឹកជ័រ សរីរសាស្ត្រទឹកជ័រ ជំងឺ និងកត្តាចង្រៃលើដំណាំកៅស៊ូ

### ៥.២. សេចក្តីសន្និដ្ឋាន

សកម្មភាព និងលទ្ធផលការងារ ដែលវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាសម្រេចបាននេះ ដោយសារមានផែនការការងារច្បាស់លាស់ និងកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងមន្ត្រីរាជការ និយោជិតទាំងអស់ ជាមួយថ្នាក់ដឹកនាំ **វសកក** ក្នុងការអនុវត្តតួនាទីភារកិច្ច និងមានការទទួលខុសត្រូវ ក្នុងបេសកកម្មរបស់ខ្លួននិងផែនការ ដែលបានកំណត់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ របស់ក្រុមប្រឹក្សាភិបាល ព្រមជាមួយគ្នានោះ ក៏មានយកចិត្តទុកដាក់ ចង្អុលបង្ហាញ និងការគាំទ្រពីស្ថាប័នជំនាញ ជាអណាព្យាបាលរួមមាន៖ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** និង **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ក្នុងការជំរុញ ការអភិវឌ្ឍន៍វិស័យកៅស៊ូនៅកម្ពុជា ស្របតាមគោលនយោបាយអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលកម្ពុជា។

សកម្មភាព និងលទ្ធផលការងារខាងលើនេះ សម្រេចបានមួយចំណែក ដោយមានការចូលរួមពីបណ្តាដៃគូជាតិ រួមមានប្រតិបត្តិករកៅស៊ូទាំងអស់ ដែលបានផ្តល់ការទុកចិត្ត ចូលរួម និងគាំទ្រ ជាងនេះទៅទៀតគឺការចូលរួមសហការ ពីបណ្តាដៃគូអន្តរជាតិពាក់ព័ន្ធដូចជា៖ CIRAD, AFD, IRRDB, HRPP, CATAS,...។

# ៦. ការប្រជុំ និងសិក្ខាសាលា

## ៦.១. ការប្រជុំ និងសិក្ខាសាលាក្នុងប្រទេស



ការប្រជុំផ្ទៃក្នុងរបស់ថ្នាក់ដឹកនាំនៃ ***វសកក*** ក្រោមអធិបតីភាព **លោក ម៉ក់ សុភាខាស្លា** នាយក ***វសកក*** ដើម្បី ពិភាក្សាអំពីវឌ្ឍភាព និងលទ្ធផល នៃការអនុវត្តការងារ ក្នុងខែចាស់ និងលើកទិសដៅ សម្រាប់អនុវត្តក្នុងខែបន្ទាប់ ដែលប្រព្រឹត្តទៅរាងរាល់មួយខែម្តង



**ឯកឧត្តម ប៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អញ្ជើញជាអធិបតីភាពដឹកនាំ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ***វសកក*** លើកទី៤ អាណត្តិទី៥ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩

ថ្ងៃចន្ទ ៦រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ បន្ទាប់ពីទទួលបានការតែងតាំង និងប្រកាសឲ្យចូលកាន់ដំណែង របស់មន្ត្រីរាជការ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដោយ **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួចមក **លោក ម៉ក់ សុភាវស្នា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានបើកកិច្ចប្រជុំនៅស្ថានីយ នៃវិទ្យាស្ថាននៅដើម្បីណែនាំ និងផ្តល់អនុសាសន៍ដល់មន្ត្រី ដែលទទួលបានការតែងតាំងថ្មី ឲ្យខិតខំបំពេញការងារតាមតួនាទី និងភារកិច្ច ដើម្បីសម្រេចបាននូវលទ្ធផលប្រកបដោយផ្លែផ្កា។



មន្ត្រី **វសកក** បានចូលរួមសិក្សាវគ្គបណ្តុះបណ្តាល ដោយជោគជ័យ លើជំនាញបច្ចេកទេស ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៩ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ





ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ លោក **ម៉ក់ សុភាថាស្នា** នាយកនៃ **វសកក** បានចូលរួមប្រជុំនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការតែងតាំងគណៈកម្មការកណ្តាល និងអនុគណៈកម្មការរៀបចំសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទូទាំងប្រទេសប្រចាំឆ្នាំ២០១៨-២០១៩ និងទិសដៅឆ្នាំ២០១៩-២០២០ ក្រោមអធិបតីភាព **ឯកឧត្តម យុទ្ធ ភូថង** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ លោក **ម៉ក់ សុភាថាស្នា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នារវាងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាមួយក្រុមហ៊ុន SOCFIN KCD ដោយមានការអញ្ជើញចូលរួមពី លោកនាយករងវិទ្យាស្ថាន មន្ត្រីជំនាញរបស់វិទ្យាស្ថាន និងលោកតំណាងក្រុមហ៊ុន SOCFIN KCD។





មន្ត្រី ***វសកក*** បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញ នៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កសិកម្ម ២០១៩-២០២៣



មន្ត្រី ***វសកក*** បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញ នៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ២០១៩-២០២៣

ពីថ្ងៃទី២២ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩ គណៈប្រតិភូនៃវេទិកាដៃគូស្រាវជ្រាវកៅស៊ូ (HRPP) បានអញ្ជើញមកទស្សនកិច្ច នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (CRRI) ក្នុងគោលបំណង ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវរួមគ្នា អំពីការកែច្នៃកៅស៊ូ។ ក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ ក្រុមការងារ HRPP និងក្រុមការងារ CRRI ក៏បានចុះសិក្សាអំពីការកែច្នៃកៅស៊ូនៅក្រុមហ៊ុនសុភក្តិនីកា អ៊ិនវេសមេន គ្រុប ខូ.,



ការប្រជុំ និងពិភាក្សា រវាង **វសកក** និង គណៈប្រតិភូនៃវេទិកាដៃគូស្រាវជ្រាវកៅស៊ូ (HRPP) ៖ អំពីកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវរួមគ្នា អំពីការកែច្នៃកៅស៊ូ



ការចុះទស្សនកិច្ចរបស់ ជំនាញការHRPP នៅមន្ទីរពិសោធជាតិយថាប្រភេទ



ក្រុមការងារ HRPP និងក្រុមការងារ CRRI ក៏បានចុះសិក្សានៅតាមបណ្តាចម្ការកៅស៊ូផ្សេងៗ

នៅថ្ងៃទី១០-១២ ខែមិថុនា ឆ្នាំ២០១៩ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការ រវាងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (CRRI) និងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំង (CIRAD) ជំនាញការ CIRAD បានអញ្ជើញមកទស្សនកិច្ច និងពិភាក្សាការងារស្រាវជ្រាវកៅស៊ូ ជាមួយមន្ត្រីស្រាវជ្រាវកៅស៊ូរបស់ CRRI នៅស្ថានីយពិសោធន៍ របស់វិទ្យាស្ថានស្ថិតក្នុងខេត្តត្បូងឃ្មុំ។ ក្នុងនោះផងដែរ ថ្នាក់ដឹកនាំ **វសកក** និងសហការី បានរួមដំណើរជាមួយជំនាញការ CIRAD ចូលរួមប្រជុំជាមួយ និងថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិកាលើការ កសាងសមត្ថភាព (capacity building) ដល់និស្សិតថ្នាក់អនុបណ្ឌិត និងបណ្ឌិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។



សកម្មភាពកិច្ចប្រជុំពិភាក្សា និងដំណើរទស្សនៈកិច្ចរបស់ជំនាញការ CIRAD នៅស្ថានីយពិសោធន៍របស់ **វសកក**



សកម្មភាពកិច្ចប្រជុំពិភាក្សា រវាងថ្នាក់ដឹកនាំ **វសកក** ជំនាញការ CIRAD  នឹងថ្នាក់ដឹកនាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិកាលើការ កសាងសមត្ថភាព (capacity building) ដល់និស្សិតថ្នាក់អនុបណ្ឌិត និងបណ្ឌិត

នៅថ្ងៃចន្ទ ១កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ **ឯកឧត្តម អៀង ស៊ុនលី** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអញ្ជើញមកពិនិត្យវឌ្ឍនភាព នៃការងារស្រាវជ្រាវកៅស៊ូនៅស្ថានីយពិសោធន៍ របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ស្ថិតនៅភូមិ៣២ ឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ **លោក ម៉ក់ សុភាវាស្នា** នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានរាយការណ៍ជូន ឯកឧត្តមអនុរដ្ឋលេខាធិការ និងសហការីជ្រាបអំពីប្រវត្តិ វឌ្ឍនភាពការស្រាវជ្រាវកៅស៊ូ បញ្ហាប្រឈម សំណូមពរ និងទិសដៅការងារ ដែលត្រូវអនុវត្តបន្ត របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។ បន្ទាប់ពីបានស្តាប់បទបង្ហាញយ៉ាងក្បោះក្បាយរបស់លោកនាយកវិទ្យាស្ថានរួចមក ឯកឧត្តមអនុរដ្ឋលេខា ដែលជាប្រធានប្រតិភូ បានកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងបំពេញការងារ របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ហើយ ឯកឧត្តម បានយល់ព្រមជួយគាំទ្រ នូវសំណូមពរមួយចំនួន របស់វិទ្យាស្ថាន។ បន្ទាប់មកទៀត ប្រតិភូទាំងអស់បានអញ្ជើញ ធ្វើទស្សនកិច្ច នៅមន្ទីរពិសោធន៍ជាតិយថាប្រភេទ រោងចក្រកែច្នៃកៅស៊ូសន្លឹក ការជួសជុលផ្ទះកម្មករ និងឡូត៍ពិសោធន៍កៅស៊ូមួយចំនួនទៀត។



**ឯកឧត្តម អៀង ស៊ុនលី** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអញ្ជើញមកពិនិត្យវឌ្ឍនភាព នៃការងារស្រាវជ្រាវកៅស៊ូ នៅស្ថានីយពិសោធន៍របស់ **វសកក** ស្ថិតនៅភូមិ៣២ ឃុំជីរោទិ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

## ៦.២. ការប្រជុំ និងសិក្ខាសាលានៅក្រៅប្រទេស

នៅថ្ងៃទី០៩-១២ ខែមេសា ឆ្នាំ២០១៩ ថ្នាក់ដឹកនាំ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានទៅចូលរួមសិក្ខាសាលា និងកិច្ចប្រជុំក្រោមប្រធានបទ *ជីជាតិដី ការអនុវត្តកសិកម្មល្អ និងផលិតកម្ម (Soil fertility, Good Agriculture Practices and Productivity) និងកិច្ចប្រជុំអ្នកជំនាញកៅស៊ូ ដើម្បីពិភាក្សា លើជំងឺកៅស៊ូ ដែលកំពុងកើតមានឡើងថ្មីៗ (IRRDB meeting of the experts on new leaf diseases )* ដែលប្រព្រឹត្តិនៅ ទីក្រុង Melaka និងទីក្រុង Kuala Lumpur ប្រទេសម៉ាឡេស៊ី ក្នុងឱកាសនេះដែរ **វសកក** បានធ្វើបទបង្ហាញលើប្រធានបទមួយ ស្តីអំពីជំងឺកៅស៊ូនៅកម្ពុជា។ គោលបំណងសំខាន់នៃសិក្ខាសាលានេះ គឺជាកាចែករំលែកចំណេះដឹង វិធីសាស្រ្តអនុវត្តកសិកម្មល្អ (GAP) ការផ្សព្វផ្សាយព័ត៌មាន និងផ្ទេរបច្ចេកវិទ្យា (TOT) នៃការរកឃើញប្រភេទដីថ្មី ក្នុងតំបន់មួយផ្សេងទៀត នៅក្នុងប្រទេសម៉ាឡេស៊ី ដែលមានអំណោយផលល្អសម្រាប់ដំណាំកៅស៊ូ។ ចំណែកគោលបំណងនៃកិច្ចប្រជុំ គឺផ្តោតសំខាន់លើប្រភេទជំងឺ និងវិធានការការពារ និងព្យាបាលជំងឺស្លឹកកៅស៊ូថ្មី (*Fusicoccum* និង *Pestalotiopsis leaf diseases*) ជំងឺនេះកំពុងរាតត្បាតនៅប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី។ អង្គសិក្ខាសាលា មានសិក្ខាកាមចូលរួមចំនួន២៥០នាក់ មកពីប្រទេសចំនួន១០ និងកិច្ចប្រជុំអ្នកជំនាញកៅស៊ូ ដើម្បីពិភាក្សាលើជំងឺកៅស៊ូ ដែលកំពុងកើតមានឡើងថ្មីៗ មានសមាជិកចូលរួមចំនួន៣៣នាក់មកពីប្រទេសឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ស្រីលង្កា ថៃ ហ្វីលីពីន វៀតណាម និងកម្ពុជា ។



រូបភាពពិពណ៌នៃសិក្ខាសាលា



រូបភាពសិក្ខាកាមចុះអនុវត្តផ្ទាល់លើកៅស៊ូគ្រួសារ



ទិដ្ឋភាពសមាជិក ចូលរួមនៃកិច្ចប្រជុំ



ថ្នាក់ដឹកនាំនៃ **វសកក** ធ្វើបទបង្ហាញអំពីជំងឺកៅស៊ូនៅកម្ពុជា

ថ្ងៃទី១៩ខែសីហា ឆ្នាំ២០១៩ លោក **ម៉ក់ សុភាទាស្លា** នាយក **វសកក** និងសហការី បានចូលរួមសិក្ខាសាលាស្តីពីបច្ចេកទេសកៅស៊ូ លើប្រធានបទស្តីពីបច្ចេកទេសក្នុងការផ្តល់ និងកែច្នៃកៅស៊ូ ចេញពីទឹកជ័រ ពីថ្ងៃទី ១៨-២៣ ខែសីហា ឆ្នាំ២០១៩ នៅសណ្ឋាគារ រ៉ាម៉ា កាដឹន ទីក្រុងបាងកក ប្រទេសថៃ។








នៅថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ លោក **ម៉ក់ សុភាចាស្វា** នាយក **វសកក** និងសហការី ចំនួន០៥រូប បានទៅចូលរួមសន្និសីទកៅស៊ូអន្តរជាតិឆ្នាំ២០១៩ និងកិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) ដែលប្រព្រឹត្តទៅនៅប្រទេសមីយ៉ាន់ម៉ា។ សន្និសីទកៅស៊ូអន្តរជាតិបានធ្វើឡើងក្រោមប្រធានបទ **"វិធីឆ្ពោះទៅមុខសម្រាប់ការប្រកួតប្រជែង និងនិរន្តរភាព"** និងការប្រជុំប្រចាំឆ្នាំនៃ IRRDB។ សន្និសីទ និងប្រជុំនេះបានចែករំលែកនូវបទពិសោធន៍ និងគន្លឹះមួយចំនួន ដើម្បីធានាចីរភាពការអភិវឌ្ឍកៅស៊ូតាមរយៈការបង្កើនផលិតភាពនៃចម្ការកៅស៊ូ ការបង្កើនផលិតភាពពលកម្ម ការអភិវឌ្ឍពូជកៅស៊ូ ការផ្តល់អនុសាសន៍ក្លូនដល់កសិករ ការធ្វើពិពិធកម្មដំណាំចន្លោះរង និងមុខដំណាំផ្សេងៗ ការគ្រប់គ្រងជីជាតិដី ការការពារជំងឺ ដើម្បីធានាចីរភាពផលិតកម្ម ការប្រមូលផលទឹកជ័រតាមលក្ខសមស្រប ការបង្កើតមុខទំនិញកៅស៊ូថ្មីប្លែកៗ ដើម្បីបង្កើនការប្រើប្រាស់កៅស៊ូធម្មជាតិ ការពង្រឹងប្រសិទ្ធិភាពគុណភាពកៅស៊ូ ការពង្រឹងសមត្ថភាពធនធានមនុស្ស ហើយនិងការការពារបរិស្ថាន។ រាល់ខ្លឹមសារទាំងអស់សំដៅលើ ការធានាចីរភាពចម្ការកៅស៊ូ រក្សាចំណូលដល់កសិករ និងបណ្តាអ្នកដាំកៅស៊ូក្នុង ខណៈដែលអាកាសធាតុមានការបម្រែបម្រួល វិបត្តិកម្លាំងពលកម្ម វិបត្តិនៃការធ្លាក់ចុះតម្លៃកៅស៊ូ និងបង្កើនសមត្ថភាពដល់អ្នកស្រាវជ្រាវ។




រូបភាពអនុស្សាវរីយ៍ប្រតិភូតំណាងប្រទេសសមាជិក



ទិដ្ឋភាពសមាជិក សមាជិកាចូលរួមក្នុងអង្គសន្និសីទ



លោកនាយកវិទ្យាស្ថាន និងសហការីចូលរួមក្នុងសន្និសីទ



លោកនាយក **វសកក** ធ្វើទបង្ហាញក្នុងសម័យប្រជុំទី៣







ទិដ្ឋភាពដំណើរការនៃកិច្ចប្រជុំប្រចាំឆ្នាំរបស់ IRRDB

វគ្គបណ្ដុះបណ្ដាលស្ដីពីការកែច្នៃផលិតផលកៅស៊ូធម្មជាតិ ដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី២១ ខែកញ្ញា ដល់ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ នៅប្រទេសថៃ និង ប្រទេសមីយ៉ានម៉ា



សកម្មភាពការណែនាំខ្លួនដល់ក្រុម Fellowship



មន្ត្រី **វសកក** បានធ្វើបទបង្ហាញ





ការទទួលវិញ្ញាបនបត្រ របស់មន្ត្រី **វសកក**



រូបថតអនុស្សាវរីយ៍ IRRDB Fellowship

## ៧. រូបភាពសកម្មភាពផ្សេងទៀត



ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **វសកក** បានចូលរួមក្នុងពិធីបើកសន្និបាតបូកសរុប ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៨ និងលើកទិសដៅ ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ










ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ លោក **ម៉ក់ សុនាវាស្នា** នាយក **វសកក** មានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយបាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ នៅក្នុងពិធីបិតសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩






ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាន ប្រកាសចូលកាន់តំណែង និងបំពាក់គ្រឿងឥស្សរិយយស ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានកៅស៊ូ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក្នុងពិធីបិទកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅអនុវត្ត ការងារឆ្នាំ២០១៩ ដែលប្រព្រឹត្តទៅនៅអគ្គនាយកដ្ឋានកៅស៊ូ

ថ្ងៃទី២៧-២៩ ខែឧសភា ឆ្នាំ២០១៩ និស្សិតមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូឆ្នាំទី២ ជំនាន់ទី៨ និង និស្សិតឆ្នាំទី៣ ជំនាន់ទី៧ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចុះកម្មសិក្សានៅស្ថានីយពិសោធន៍ និងមន្ទីពិសោធន៍ ជាតិយថាប្រភេទ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។



សកម្មភាពនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចុះកម្មសិក្សា នៅស្ថានីយពិសោធន៍
និងមន្ទពិសោធន៍ជាតិយថាប្រភេទ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ គណៈប្រតិភូនៃសាកលវិទ្យាល័យ Prince of Songkla បានអញ្ជើញមកទស្សនកិច្ចនៅស្ថានីយពិសោធន៍ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (CRRI) ក្នុងគោលបំណងដើម្បីស្វែងយល់អំពីការអភិវឌ្ឍន៍ដំណាំកៅស៊ូ និងការផ្ទេរបច្ចេកវិទ្យាដល់អ្នកដាំដុះកៅស៊ូនៅប្រទេសកម្ពុជា











# សកម្មភាពការថែទាំ និងដាំដុះដំណាំកៅស៊ូ ឆ្នាំ២០១៩



ការដាំដុះឆ្នាំ២០១៩



ការជំរះវ៉ែករងកូនកៅស៊ូដាំឆ្នាំ២០១៩



ការជួសកូនកៅស៊ូ



សកម្មភាពបាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកូលាប



ច្រកដីនៅថ្នាលបណ្ដុះកូនកៅស៊ូ ឆ្នាំ ២០១៩-២០២០



ការរៀបចំថ្នាលបណ្ដុះគ្រាប់

# រូបភាពសកម្មភាពការងាររបស់មន្ត្រី នៅការិយាល័យបង្កាត់ពូជឆ្នាំ២០១៩



សកម្មភាពបង្រៀននិស្សិតសាលាកសិកម្មកំពង់ចាម



ថែទាំច្បារពូជកៅស៊ូសម្រាប់បម្រើដល់ការពិសោធ



លូនកៅស៊ូផ្ញើរទៅRRI-CATAS



ចុះអង្កេតពីការប្រើប្រាស់ក្លូនកៅស៊ូតាមបណ្តាខេត្ត



សកម្មភាពវាស់ទំហំដើមកៅស៊ូ



ការបំប៉ៅក្លូនកៅស៊ូមកពីRRI-CATAS

# រូបភាពសកម្មភាពការងាររបស់មន្ត្រីការិយាល័យសរីរវិទ្យា និងអាជីវកម្ម



សកម្មភាពវាស់ទំហំដើមតាមដានការលូតលាស់



សកម្មភាពវាស់ជំងឺស្ងួតមុខចៀរ



សកម្មភាពវិភាគរកបរិមាណជ័រកៅស៊ូស្ងួត
(DRC) តាមឧបករណ៍មេត្រូឡាក់



សកម្មភាពដាក់ជីព្យាបាលជំងឺស្ងួតមុខចៀរ



ការបង្ហាញអំពីរបៀបនៃការយកសំណាកទឹកជ័រ
នៅចម្ការពិសោធន៍ខេត្តមណ្ឌលគិរី



ថ្នាក់ដឹកនាំការិយាល័យធ្វើបទបង្ហាញក្នុងសន្និសីទ
កៅស៊ូ អន្តរជាតិឆ្នាំ២០១៩ នៅប្រទេសមីយ៉ាន់ម៉ា

# រូបភាពសកម្មភាពចុះពិនិត្យរោងចក្រកែច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍ មូលដ្ឋាននៃក្រុមហ៊ុនស៊ីហ្វ វីសសស៍ (ខេមបូឌា) លីមីធីត



សកម្មភាពពិនិត្យទឹកជ័រមកពីចម្ការ



សកម្មភាពពិនិត្យទិន្នន័យធ្វើ DRC ពីចម្ការ



សកម្មភាពពិនិត្យការបង្ហូរជ័រចូលអាងបង្កក



សកម្មភាពពិនិត្យឯកសារមន្ទីរពិសោធន៍



រូបអនុស្សាវរីយ៍ក្រុមបេសកកម្មនៅមន្ទីរពិសោធន៍ មូលដ្ឋាននៃក្រុមហ៊ុនស៊ីហ្វ វីសសស៍ (ខេមបូឌា) លីមីធីត

# មន្ត្រី វសកក ចុះពិនិត្យរោងចក្រ និងមន្ទីរពិសោធន៍ ក្នុងការអនុវត្តនិតិវិធីនៃការចុះបញ្ជិការោងច្នៃកៅស៊ូ CSR និងមន្ទីរពិសោធន៍មូលដ្ឋានតាមក្រុមហ៊ុននិមួយៗដើម្បីទទួលសិទ្ធប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា (CSR)













សកម្មភាពពិនិត្យនិងវាយតម្លៃ កន្លែងស្តុកជ័រកៅស៊ូ



**ឯកឧត្តម ប៉ុល សុផា** ប្រតិភូរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយដ្ឋានកៅស៊ូ បានចុះទស្សនកិច្ចនៅស្ថានីយ៍អនុវត្ត  នៃវិទ្យាស្ថានស្រាវជ្រាកៅស៊ូកម្ពុជា ដែលមាទីតាំងស្ថិតនៅភូមិ៣២ ឃុំជីរោទ៍២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ





នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ បានទទួលក្រុមការងារមកពីអគ្គនាយកដ្ឋានកៅស៊ូចំនួន០៥នាក់ មកពិនិត្យមើលវឌ្ឍនភាព និងវាតម្លៃនូវលទ្ធផលនៃការអនុវត្តការងារ និងការវិវឌ្ឍន៍ស្ថានភាព របស់ចម្ការពិសោធន៍បង្ហាញព្រមទាំងប្រជុំពិភាក្សា ដើម្បីកំណត់ទៅទិសដៅបន្តអនុវត្តន៍ចម្ការពិសោធន៍បង្ហាញ តាមខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងអគ្គនាយកដ្ឋានកៅស៊ូ(GDR) និងវិទ្យស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(CRRI)។